| ៤៥៥- លោកស្រី | សំប្បូរ សាឌី | ៤៥៦- លោកស្រី | ចិន ណារិន |
| ៤៥៧- លោកស្រី | គង គែម | ៤៥៨- កញ្ញា | អ៊ឹម ប៊ុណ្ណារី |
| ៤៥៩- លោក | កែន ផាន់ | ៤៦០- លោក | អំ ប៉ាត |
| ៤៦១- លោក | អ៊ុម សឿង | ៤៦២- លោក | គេង សុថា |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស/រកត.០២០៩.១៤៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩*

លេខ: ១៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ម៉ម សារិន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តម សោម សឿន
២- ឯកឧត្តម គាត ស៊ុនអ៊ី
៣- ឯកឧត្តម កែ ប៊ុនខៀង
៤- ឯកឧត្តម ញាណ ឡេង
៥- ឯកឧត្តម សិទ្ធ សារុន

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- ឯកឧត្តម ប៊ូ យឿង
២- ឯកឧត្តម ហ៊ុត ស៊ីដ

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- ឯកឧត្តម ឆ សោ
២- ឯកឧត្តម ថោង ឃិន
៣- ឯកឧត្តម គីម ហេង
៤- លោកជំទាវ ហោ ម៉ាលីន
៥- លោក គង់ សម្បត្តិ
៦- ឯកឧត្តម ហេង សម័យ
៧- លោក អ៊ិត គីមហាន
៨- លោក អេង ណាង
៩- លោក ឈួប អ៊ុយ
១០- លោក ឡុច សារិន
១១- លោក ពេជ ច័ន្ទរិទ្ធ
១២- លោក ម៉ឹង សុខណ្ណា
១៣- លោក ហ៊ឹម យ៉ានី
១៤- លោក កែង ឆាន់
១៥- លោក ហោ ភួន
១៦- លោក ភិន សុភាន់
១៧- លោកស្រី សឿ ច័ន្ទថា
១៨- លោក នង សេង
១៩- លោក ម៉ាត់ ស៊ាន
២០- លោក ហ៊ឹម សឿត

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

២១- លោកស្រី ស្វស បៀង
២២- លោក សៅ ផាន
២៣- លោក ហាឡុ ឡូ
២៤- លោក កែច សីហ៊ុល
២៥- លោក ចណ្ណ សុធា
២៦- លោកស្រី ឈាំ ឌីម
២៧- លោក គួត គន្ធ
២៨- លោក ចាន់ ផន
២៩- លោក ខៀវ សារុន
៣០- លោក គង់ បូរ៉ា
៣១- លោក ស៊ុំ សៀង
៣២- លោក ពោន ពន្លឺ
៣៣- លោក នូ សិន
៣៤- លោក មាស គ្រួច
៣៥- លោក នាង សុផល
៣៦- លោក ជ័យ ប៊ុន
៣៧- លោក អាំ ផន
៣៨- លោក ចត់ ចាន់តន
៣៩- កញ្ញា ម៉ែន សុភារី
៤០- អ្នកស្រី ស្រី សារុន
៤១- លោក ឌី គីន
៤២- លោក យស់ សុខនី
៤៣- លោក ស៊ិន សម្បត្តិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/០២០៩/១៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩

លេខ : ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

| | |
|---|---|
| ១- សាលារាជធានីភ្នំពេញ | ២- សាលាខេត្ត កណ្តាល |
| ៣- សាលាខេត្ត ក្រចេះ | ៤- សាលាខេត្ត កែប |
| ៥- សាលាខេត្ត កំពង់ចាម | ៦- សាលាខេត្ត កំពង់ឆ្នាំង |
| ៧- សាលាខេត្ត កំពង់ធំ | ៨- សាលាខេត្ត កំពង់ស្ពឺ |
| ៩- សាលាខេត្ត កំពត | ១០- សាលាខេត្ត កោះកុង |
| ១១- សាលាខេត្ត តាកែវ | ១២- សាលាខេត្ត បន្ទាយមានជ័យ |
| ១៣- សាលាខេត្ត បាត់ដំបង | ១៤- សាលាខេត្ត ប៉ៃលិន |
| ១៥- សាលាខេត្ត ព្រៃវែង | ១៦- សាលាខេត្ត ពោធិ៍សាត់ |
| ១៧- សាលាខេត្ត ព្រះសីហនុ | ១៨- សាលាខេត្ត ព្រះវិហារ |
| ១៩- សាលាខេត្ត មណ្ឌលគិរី | ២០- សាលាខេត្ត រតនគិរី |
| ២១- សាលាខេត្ត ស្វាយរៀង | ២២- សាលាខេត្ត ស្ទឹងត្រែង |
| ២៣- សាលាខេត្ត សៀមរាប | ២៤- សាលាខេត្ត ឧត្តរមានជ័យ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០២.១៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩

លេខ : ១៤៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៤៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម **ហ៊ុន ណេង**

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣.៧.០៩០២.១៤៩

លេខ ១៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៤៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ឆ្លូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-

១-ឯកឧត្តម បណ្ឌិត សាត សាមី　　២-ឧត្តមសេនីយ៍ឯក សំ វណ្ណថន

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-

ឧត្តមសេនីយ៍ទោ កៅ ធ្វើ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

១-ឧត្តមសេនីយ៍ទោ ង៉ែត នរិន្ទ　　២-លោក សេង រតនះ

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :-

លោក មាស សឿន

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

| | |
|---|---|
| ១-ឧត្តមសេនីយ៍ត្រី សេរី តាក់តើ | ៥-ឧត្តមសេនីយ៍ត្រី អ៊ូ ដាន់ឌី |
| ២-ឧត្តមសេនីយ៍ត្រី ទឹម សុខ | ៦-ឧត្តមសេនីយ៍ឯក សោម សុះជត |
| ៣-ឧត្តមសេនីយ៍ត្រី ជា សំអឿន | ៧-វរសេនីយ៍ឯក ជា ស៊ីថន |
| ៤-វរសេនីយ៍ឯក ម៉ុល សុគុណ | ៨-វរសេនីយ៍ទោ ខាត់ សុផល |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

| | |
|---|---|
| ១-វរសេនីយ៍ឯក កេរ្ត៍ សារឿន | ៤-វរសេនីយ៍ទោ ចាន់ ដេង |
| ២-វរសេនីយ៍ទោ ពុទ្ធ ទាសនា | ៥-វរសេនីយ៍ទោ មាស សាវ៉ាត |
| ៣-វរសេនីយ៍ទោ យ៉ុង ធីរាវុឌ្ឍ | |

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

១-ឯកឧត្តម កែវ ណាប　　២-វរសេនីយ៍ត្រី គី គីមសាន

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩*

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

៣៧៧.០៩០២.១៥០

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ ១៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ៥.២៧៣ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀវ និងការធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១: -**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរ លើផ្ទៃដីទំហំ **បួនពាន់ពីររយចិតសិបបី (៤.២៧៣) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដូចមានក្នុងផែនទី និងនិយាមកាជូនភ្ជាប់មកជាមួយ សម្រាប់ផ្តល់ឱ្យក្រុមហ៊ុន **សេដ្ឋិកុលា** (SETHIKULA Co.,Ltd) រយៈពេល ៩៩ឆ្នាំ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ ។

**មាត្រា២: -**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ **បួនពាន់ពីររយចិតសិបបី (៤.២៧៣) ហិកតា** ដូចមានក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរដែនដី ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយសាលានាយទាហានចម្រុះ
## ទៅជា វិទ្យាស្ថានទ័ពជើងគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៩

# សម្រេច

**មាត្រា ១.-**

ត្រូវបានប្រែក្លាយសាលានាយទាហានចម្រុះ ទៅជាវិទ្យាស្ថានទ័ពជើងគោក មានកម្រិតស្មើគ្រឹះស្ថានឧត្ដមសិក្សា ។ វិទ្យាស្ថានទ័ពជើងគោក សរសេរអក្សរកាត់ថា **វ.ឧ.ជ.គ.** ។ **វ.ឧ.ជ.គ.** មានទីតាំងបច្ចុប្បន្ននៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ២.-**

វិទ្យាស្ថានទ័ពជើងគោក មានតួនាទីនិងភារកិច្ចបណ្ដុះបណ្ដាល នាយទាហានបម្រើទ័ពជើងគោក និងស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសយោធា ចំណេះដឹងទូទៅដល់កម្រិត បរិញ្ញាបត្ររង បរិញ្ញាបត្រ និងវិក្រឹតការ លើមុខជំនាញកងទ័ពជើងគោក ។ វ.ឧ.ជ.គ. ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និងគ្រប់មុខជំនាញតាមផែនការរបស់ក្រសួងការពារជាតិ ។

**មាត្រា ៣.-**

វិទ្យាស្ថានទ័ពជើងគោក ស្ថិតនៅក្រោមការគ្រប់គ្រង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។ វិទ្យាស្ថានទ័ពជើងគោក ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

វិទ្យាស្ថានទ័ពជើងគោក មានថ្នាក់បណ្ដុះបណ្ដាល និង វគ្គវិក្រឹតការនាយទាហានបម្រើទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ តាមមុខជំនាញ ដូចខាងក្រោម ៖

- បញ្ជាការ ថ្មើរជើង
- បញ្ជាការ ស៊ើបការ
- បញ្ជាការ រថក្រោះ រថពាសដែក
- បញ្ជាការ កាំភ្លើងធំ
- បញ្ជាការ ការពារអាកាស
- បញ្ជាការ វិស្វកម្ម
- បញ្ជាការ បញ្ជូនសារ
- បញ្ជាការ គីមីសាស្ត្រ
- បញ្ជាការ ការពារព្រំដែន ។

ទៅអនាគត យោងតាមសេចក្ដីត្រូវការចាំបាច់ក្នុងវិស័យការពារជាតិ វិទ្យាស្ថាននេះ អាចបន្ថែមមុខជំនាញដទៃទៀត ដោយអនុលោមតាមមាត្រា ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

លក្ខខណ្ឌជ្រើសរើស សិស្ស និស្សិត និងយោធិន ឱ្យចូលសិក្សានៅវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ឱ្យបានសមស្របទៅតាមបទដ្ឋាន ស្ដីពីការកំណត់លក្ខខណ្ឌ នៃការចូលរៀននៅឧត្ដមសិក្សា និងមធ្យមសិក្សាឯកទេស ។

**មាត្រា ៦._**

និស្សិតនាយទាហានបឋម ដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានទ័ពជើងគោក ហើយបានប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។

សញ្ញាបត្របញ្ចប់ការសិក្សា នៃវិទ្យាស្ថានទ័ពជើងគោក មានតម្លៃសមមូល បរិញ្ញាបត្ររង បរិញ្ញាបត្រ នៃកម្រិតបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សា ។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខាដោយនាយកវិទ្យាស្ថានទ័ពជើងគោក និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៧._**

ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវសហការក្នុងការរៀបចំកម្មវិធីសិក្សា និងជ្រើសរើសគ្រូឧត្តមសិក្សា និងសាស្ត្រាចារ្យ មកបង្រៀននៅវិទ្យាស្ថានទ័ពជើងគោកតាមតម្រូវការ និងភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស ក្នុងកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៨._**

ការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៩._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៨៥ អនក្រ.តត**

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា១** : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-ឧត្តមសេនីយ៍ឯក ទៅ សុឈ អត្តលេខ ០០១០៩៨ ជា នាយរងសេនាធិការចំរុះបន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ឯក សោម ចូរិន្ទ អត្តលេខ ០០០១៥៧ ជា នាយក ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន

៣-ឧត្តមសេនីយ៍ឯក នូ ស៊ុន អត្តលេខ ០០០០៨៦ ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

៤-ឧត្តមសេនីយ៍ទោ សៀក សុជាតិ អត្តលេខ ០០៥២០៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៥-ឧត្តមសេនីយ៍ទោ **ខឿន ចន** អត្តលេខ ០០១៩៣៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៦-ឧត្តមសេនីយ៍ត្រី **មឹម សំ** អត្តលេខ ០០២៥១២ ជា នាយក ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្ដា សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជនជប៉ុន ចំនួន០៤រូប ដែលបានផ្តល់ថវិកា សំរាប់ដឹកជញ្ជូនសំភារៈសិក្សា តុ កៅអី ជាអំណោយពីប្រទេសជប៉ុន មកប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០០០-២០០៨ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- Mr. | TATENO | Junzo | ថវិកា ចំនួន ១៦០.០០០ ដុល្លារ |
| ២- Mr. | KAWAI | Toshihisa | ថវិកា ចំនួន ១២៧.៨៥០ ដុល្លារ |
| ៣- Mr. | SAITO | Isao | ថវិកា ចំនួន ១២៧.៨៥០ ដុល្លារ |
| ៤- Mr. | AIKAWA | Kenji | ថវិកា ចំនួន ១១៣.៥៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៨៧ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសាស្ត្រាចារ្យឧត្តមសិក្សា ចំនួន ០៩ រូប ដែលមានស្នាដៃល្អ ក្នុងការបង្រៀនសិស្ស នាយទាហានសកម្មជំនាន់ទី ៧.៨.៩.១០ និង ១១ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | បណ្ឌិត | **ឈុន ពេញ** | សេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ២- | អនុបណ្ឌិត | **នួន ផល្លា** | សេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៣- | អនុបណ្ឌិត | **ម៉ម ចរិយាឧុង** | សេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៤- | អនុបណ្ឌិត | **ឡុច ប៊ុណ្ណាស៊ីរីវត្ត** | ច្បាប់ការពារបេតិកភ័ណ្ឌជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៥- | អនុបណ្ឌិត | **ស្ពាន់ ទីន** | បរិស្ថាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦- | អនុបណ្ឌិត | **ឃាម គីមគង់** | បរិស្ថាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧- | អនុបណ្ឌិត | **ប៊ុន នឿន** | ពេទ្យសត្វ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨- | អនុបណ្ឌិត | **ពាន សុខា** | ការថែទាំដំណាំ សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩- | អនុបណ្ឌិត | **ទ៉ា បូណារ៉ា** | គណនេយ្យហិរញ្ញវត្ថុ សាកលវិទ្យាល័យជាតិគ្រប់គ្រង |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៨៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០៥ គ្រឿង ជូននាយទាហាន វេជ្ជបណ្ឌិត និង វិស្វករ នៃកងទ័ពរំដោះប្រជាជនចិន ចំនួន ០៥ រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជួយបង្ហាត់បង្រៀនវេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យព្រះកេតុមាលា សម្រេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ឯកពិសេស | ម៉ី ជៀន | MEI JIAN | វេជ្ជបណ្ឌិត ប្រធានផ្នែកបេះដូង |
| ២- | វរសេនីយ៍ឯកពិសេស | ស៊ូ វ៉ីដុង | XU WEIDONG | វេជ្ជបណ្ឌិត ប្រធានផ្នែកអេកូសាស្ត្រ |
| ៣- | វរសេនីយ៍ឯកពិសេស | ជូ យេ | ZHU YUE | វេជ្ជបណ្ឌិតអនុប្រធានផ្នែកលាងឈាម |
| ៤- | វរសេនីយ៍ឯកពិសេស | វ៉ាង អានមីង | WANG AN MING | វេជ្ជបណ្ឌិតអនុប្រធានផ្នែកវិទ្យុសាស្ត្រ |
| ៥- | វរសេនីយ៍ទោ | ហ៊ូ ស៊ាវភីង | HU XIAO PING | ប្រធានផ្នែកវិស្វកម្ម |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៨៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

ររ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានឧបត្ថម្ភថវិកាក្នុងការជួយសាងសង់អគារសិក្សាថ្មីមួយចំនួនជួយដល់វិស័យអប់រំនៅកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១- លោកស្រី **CHENDA SMEAD** បានផ្តល់ថវិកាចំនួន ១៣.០០០ ដុល្លាអារមេរិក ក្នុងការកសាងអគារសិក្សាចំនួន០១ខ្នង មាន០៥បន្ទប់ ជូនអនុវិទ្យាល័យពោធិបន្ទាយជ័យ ស្ថិតនៅភូមិពោធិ ឃុំសៀមរាប ស្រុកសៀមរាប និងថវិកា ៥០.០០០ដុល្លារអាមេរិក ជួយកសាងមជ្ឈមណ្ឌលសិក្សា០៣ជាន់នៅមណ្ឌលផ្ទះកុមារអនាគតល្អ ស្ថិតនៅភូមិព្រែកជាងព្រំ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

២- លោកស្រី **VANNY CLAY** បានផ្តល់ថវិកាចំនួន១៣.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាចុងរ៉ា ស្ថិតនៅភូមិកាលៀង ស្រុកលំផាត់ ខេត្តរតនគីរី និងថវិកាចំនួន១០.០០០ដុល្លារអាមេរិករួមចំណែកកសាងអន្តេវាសិកដ្ឋាននារីនៅមណ្ឌលផ្ទះកុមារអនាគតល្អ ។

៣-លោក **FRANK SURGENER** ប្រធានអង្គការ Rideaid នៅប្រទេសអូស្ត្រាលី បានរួមចំណែកផ្តល់ថវិកាចំនួន ១៩.៩៨៥ ដុល្លារអាមេរិក សាងសង់សាលារៀន០៤ខ្នង ស្ថិតនៅខេត្តកំពតចំនួន០២ខ្នង កោះកុង០១ខ្នង និងខេត្តរតនគីរី០១ខ្នង និងថវិកាចំនួន ២៤.៩៧៥ ដុល្លារអាមេរិក កសាងការិយាល័យ០១ខ្នង សម្រាប់ធ្វើជាទីស្នាក់ការស្ត្រីគួរមានក្តីប្រាថ្នាខ្ពស់ ធ្វើបណ្ណាល័យ និងទិញរថយន្ត០១គ្រឿង ។

៤-កញ្ញា **RACHEL ROSENFELD** បានផ្តល់ថវិកាចំនួន ៥១.៩៣១ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សាស្រះខ្វាវ ស្ថិតនៅភូមិស្រះខ្វាវ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងរួមចំណែកកសាងអន្តេវាសិកដ្ឋាននារី នៅមណ្ឌលផ្ទះកុមារអនាគតល្អ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។ /៕/

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩០ អនក្រ.តត**

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **កែប កំណ្ណារុ** ប្រធានគ្រប់គ្រងកម្មវិធីអង្គការប៉ាដិក ដែលបានជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បំពាក់គ្រឿងសង្ហារឹមគ្រប់បន្ទប់ និងបង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាតាសោម ស្ថិតនៅភូមិតាសោម ឃុំតាសោម ស្រុកអង្គរជុំ ខេត្តសៀមរាប ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ណឹម ម៉េង** ទីប្រឹក្សាឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងជាប្រធានកិត្តិយសគណៈកម្មការទ្រទ្រង់វិទ្យាល័យ ជា ស៊ីម សាមគ្គី ដែលបានជួយឧបត្ថម្ភថវិកាសំរាប់អភិវឌ្ឍន៍វិស័យសិក្សាធិការ នៅវិទ្យាល័យ ជា ស៊ីម សាមគ្គី រាជធានីភ្នំពេញ រួមមាន : ស្តូបនិងរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ សួនច្បារ ដងទង់ជាតិ ខ្លោងទ្វារធំ ០១ តុវេទិកា "តុវាគ្មិន" រៀបក្រាលការ៉ូឡា មុខអាគារទី៥ និងចាក់ដីបំពេញទីធ្លា សរុបថវិកាអស់ចំនួន ២១.៨០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**សម្រេច**

**មាត្រា១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី YOSHIDA YOSHIKO ដែលបានឧបត្ថម្ភថវិកាចំនួន ៣១.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ ដំបូលប្រក់ក្បឿង បំពាក់ក្តារខៀន តុ-កៅអីសម្រាប់គ្រូ-សិស្ស ធ្វើខ្លោងទ្វារ ដងទង់ជាតិ និងបង្គន់អនាម័យ ០១បន្ទប់ ជូនដល់សាលាបឋមសិក្សាព្រៃឆ្កា ស្ថិតនៅភូមិព្រៃឆ្កា ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប ។

**មាត្រា២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន និងអង្គការដែលបានឧបត្ថម្ភថវិកា ចំនួន ២៥.៨៥០ ដុល្លារអាមេរិក តាមរយៈអង្គការសន្តិស្ម័គ្រចិត្ត ក្នុងការជួយសាងសង់អគារបណ្ណាល័យ ចំនួន ០១ខ្នង សង់អំពីថ្មប្រក់ក្បឿង បង្គន់អនាម័យ តបណ្តាញទឹក និងតបណ្តាញអគ្គិសនី ជូនដល់សាលាបឋមសិក្សាអនុវត្ត ចំណុះឱ្យសាលាគរុកោសល្យ និងវិក្រឹតការខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-ក្រុមហ៊ុន GENMAIKOSO COMPANY JAPAN

២-អង្គការ SHANTI VOLUNTEER ASSOCIATION

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**សម្រេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី YONEKURA YOSHIKO សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកាចំនួន ៣៨.៧៧៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ និងអណ្តូងទឹកស្អាត ០១ ជូនដល់សាលាបឋមសិក្សាកំរ៉ែង ឃុំព្រែកជីក ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន SANTE CREAR Co., Ltd. ដែលបានឧបត្ថម្ភថវិកាចំនួន ៣៦.៥២០ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ ជូនដល់អនុវិទ្យាល័យដំណាក់ត្រាច ស្ថិតនៅភូមិដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន០២រូប ដែលបានឧបត្ថម្ភថវិកាចំនួន ៤២.៦០៩ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៦បន្ទប់ បង្គន់អនាម័យ ០២បន្ទប់ ព្រមទាំងបំពាក់តុ-កៅអីគ្រប់គ្រាន់ជូនដល់សាលាបឋមសិក្សាវត្តកក់ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម SHINOHARA KATSUHIRO ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
២- លោក WATANEBE MIKI អគ្គនាយកអង្គការ SCHOOL AID JAPAN

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៣គ្រឿង ជូនសមាគម និងសប្បុរសជន ដែលបានផ្តល់ថវិកា ចំនួន ៣១.៧០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ សង់អំពីថ្ម ប្រក់ស័ង្កសី ព្រមទាំងបំពាក់គ្រឿងសង្ហារឹម និង បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាស្មើ ស្ថិតនៅឃុំស្មើ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-**សមាគមមូលនិធិសង្គ្រោះនិស្សិតខ្មែរ នៅកាណាដា**
២-លោក **ឡុត សំឡី**
៣-**SAY ALIDETH SANH**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន Circle K Sunkus Co., Ltd ដែលបាន ឧបត្ថម្ភថវិកាចំនួន ៦៧.៨០០ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០២ខ្នង មាន០៩បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន ០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម គ្រប់គ្រាន់ និងអណ្តូងទឹកស្អាត ០១ ជូនដល់អនុវិទ្យាល័យស្ទឹងជ្រៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ /៚

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានឧបត្ថម្ភថវិកាក្នុងការជួយសាងសង់អគារសិក្សា ជូនដល់សាលាមួយចំនួនក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :-

១-លោក WATANABE MIKI អគ្គនាយកអង្គការ School Aid Japan បានឧបត្ថម្ភថវិកាចំនួន ២៣.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន ០៣បន្ទប់ ជូនដល់សាលាបឋមសិក្សាទួលខ្ពស់ ស្ថិតនៅភូមិប៉ប៉ិត ឃុំអន្លង់ត្នោត ។

២-លោក SHIMIZU KAZUO សប្បុរសជនបាន ឧបត្ថម្ភថវិកា ចំនួន ៣៥.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន ០៥បន្ទប់ ជូនដល់អនុវិទ្យាល័យព្រះសីហនុ ស្ថិតនៅភូមិឈើទាលខ្ពស់ ឃុំក្បាលត្រាច ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក YAMAZAKI YUJI និងភរិយា ដែលបានឧបត្ថម្ភថវិកាចំនួន ១៨.៩៩៥.៥០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន ០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់បន្ទប់ និងធ្វើខ្លោងទ្វារ ជូនដល់សាលាបឋមសិក្សាប្រសប់លាក់ ស្ថិតនៅឃុំបាទី ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន MARUEI TRADING COMPANY Ltd ដែលបានឧបត្ថម្ភថវិកា ចំនួន ៥៧.៧៦០ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយសាងសង់ អគារសិក្សា ចំនួន ០២ខ្នង មាន០៨បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន ០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿង សង្ហារឹមគ្រប់គ្រាន់ ជូនដល់អនុវិទ្យាល័យគតីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ២ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **World Vision** ដែលបានផ្តល់ថវិកា ចំនួន ៣១.២៦៨ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បំពាក់តុជើងម៉ាសិស្ស ចំនួន១២០គ្រឿង តុកៅអីគ្រូ ចំនួន ០៥គ្រឿង ក្តារខៀន ចំនួន០៥ និងទូសម្ភារៈ ចំនួន០៥ ជូនដល់សាលាបឋមសិក្សាក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម SANTIPHEAP MIYAGI VOLUNTEER ASSOCIATION ដែលបានឧបត្ថម្ភថវិកា ចំនួន ២២.៤៩៦.១៨ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន ០៣បន្ទប់ ព្រមទាំងបំពាក់ក្តារខៀន តុ-កៅអីសម្រាប់គ្រូ-សិស្ស បង្គន់អនាម័យ ០៤បន្ទប់ និង អណ្តូងទឹក ០១ ជូនដល់សាលាបឋមសិក្សាបឹងវៀន ស្ថិតនៅភូមិបឹងវៀន ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន " GAKKO E IKO!MAX ", TOKYO BROADCASTING SYSTEM ដែលបានឧបត្ថម្ភថវិកា ចំនួន ៣៨.៣៥៦ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៤បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាជូននាគស្ថិតក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២០៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម RYUUKOKU-JI TEMPLE ដែលបានឧបត្ថម្ភថវិកាចំនួន ១០.៦០៦.៩៣ ដុល្លារអាមេរិក ក្នុងការចូលរួមជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ បង្គន់អនាម័យ០៤បន្ទប់ និងជីកស្រះទឹក០១ ជូនដល់សាលា បឋមសិក្សាចំបក់ ស្ថិតនៅភូមិចំបក់ ឃុំល្វែងឫស្សី ស្រុកជីក្រែង ខេត្តសៀមរាប ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible]ភៈ ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន MAERSK [CAMBODIA] Co., Ltd. ដែលបានឧបត្ថម្ភថវិកាចំនួន ១២.០១៣ ដុល្លារអាមេរិក ក្នុងការជួយសាងសង់ទីចាត់ការចំនួន ០១ខ្នង ជូនដល់សាលាបឋមសិក្សាស្លាបលែង ស្ថិតនៅឃុំស្វាយរំពា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Mr. **TANIMURA SHOKI**, President JUMBO TOURS Co., Ltd ដែលបានឧបត្ថម្ភថវិកា ចំនួន ៣៥.៧៣១ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៦បន្ទប់ ដំបូលដែក ប្រក់ក្បឿងថៃ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ ខ្លោងទ្វារ ដងទង់ជាតិ បង្គន់អនាម័យ០២បន្ទប់ និងអណ្តូងទឹក០១ ជូនដល់សាលាបឋមសិក្សាព្រៃលាន-ចាំបូទូរស៊ី ស្ថិតក្នុងភូមិថ្មល់ចែក ឃុំពពេល ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ /ឈ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានឧបត្ថម្ភថវិកាចំនួន ៣៣.៤០០ ដុល្លារអាមេរិក តាមរយៈអង្គការ PADEK ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន ០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៣បន្ទប់ ជូនដល់សាលាបឋមសិក្សាបឹងសាឡាំ ឃុំពោធិ៍ម្រាល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| ១-លោក TON MEIJERS | សប្បុរសជន |
| ២- លោកស្រី MAAIKE DE LOOR | សប្បុរសជន |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន០៧រូប ដែលបានឧបត្ថម្ភថវិកា ចំនួន ៧៧.៣២៨ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ ទីចាត់ការ ០១ខ្នង មាន០២បន្ទប់ រោងបាយ ០១ខ្នង និងកែលំអបរិស្ថាន ជូនដល់សាលាបឋមសិក្សាចំការស្លែង ស្ថិតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

1-Mr. TAI CHIN WEN
2-Mr. GAN BOON CHYE
3-Mr. ROLANG TAN
4-Mr. ALBERT ANG
5-Mr. CHIM NGOUN
6-Mr. TAI CHIN CHUN
7-Mr. CHIAM JUN KIAT

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំង សមាសភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៨៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## ស ម្រេ ច

**ប្រការ១ :**

ត្រូវបានតែងតាំងជាសមាជិកភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១. លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| ២. លោកជំទាវ **ខ្ញូ ម៉ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

| | | |
|---|---|---|
| ៣. លោកជំទាវ ចាន់ សុន្ធាវី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤. លោកជំទាវ ចំន្ទ សូរីយ៍ | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ៥. លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ៦. លោកជំទាវ ស៊ុន សារឿន | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ៧. លោកជំទាវ អឿង សម្ភុណា | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ៨. ឯកឧត្តម អ៊ុន ចន្ថា | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩. លោកជំទាវ ម៉ិញ កុសនី | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិកា |
| ១០. ឯកឧត្តម សាស្ត្រាចារ្យ អេង ហួត | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១១. ឯកឧត្តម ចាវច់ ផែន | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១២. ឯកឧត្តម អ៊ូ ឱហាត | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៣. ឯកឧត្តម តោ សឿត | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៤. ឯកឧត្តម ឱម គីមសា | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥. ឯកឧត្តម ញ៉ឹក ច្រឹង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៦. ឯកឧត្តម ធឹក គ្រឿនវុទ្ធា | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៧. ឯកឧត្តម ពេជ្រ ប៊ុនធិន | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១៨. ឯកឧត្តម គឹម កុសល | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៩. លោកជំទាវ សុខ ចិន្ទាយ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ២០. ឯកឧត្តម លី អៀមឡាក់ | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. លោកជំទាវ សម មុន្នីកា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ២២. លោកជំទាវ តឹកវ៉េត កំរេង | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ២៣. លោកជំទាវ ស៊ឹម ខេខខាំ | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ | សមាជិកា |
| ២៤. ឯកឧត្តម ចាន់ មិន | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ២៥. លោកជំទាវ ចំន្ទ ហារ៉ានវឌ្ឍី | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិកា |

**ប្រការ២ :**

សមាជិក សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនេះមានភារកិច្ចអនុវត្តការងារទៅតាមការតំរង់ទិស នៃព្រះរាជក្រឹត្យលេខ នស / រកត /០៨០៥ / ៣៨៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៣ :**

សេចក្តីសម្រេចលេខ ៦២ សសរ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិក សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ១ និងប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧ . សសរ**

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីសកម្មភាពមជ្ឈមណ្ឌលកំសាន្ត ឬក្លឹបកំសាន្តដែលមានបំពាក់ម៉ាស៊ីនអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ
- បានឃើញសារាចរណែនាំលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)
- យោងសេចក្តីជូនដំណឹងលេខ៦៦ សជណ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព ដែលមាន សមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| -ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | ជាប្រធាន |
| -ឯកឧត្តម គាត ស្មើ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| -ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| -ឯកឧត្តម ឆិត ចន្ថា | តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| -ឯកឧត្តម ម៉ិន ផារម្ងន្ធិ | តំណាងខេត្តសៀមរាប | ជាសមាជិក |
| -លោក កើត ឆែ | តំណាងសាលាក្រុងភ្នំពេញ | ជាសមាជិក |
| -តំណាងខេត្ត-ក្រុង ពាក់ព័ន្ធ | | ជាសមាជិក |

**ប្រការ២ :** គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំ របស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព មានតួនាទី និងភារកិច្ចដូចខាងក្រោម:

១-ត្រួតពិនិត្យអាជ្ញាប័ណ្ណធ្វើអាជីវកម្មរបស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន)។

២-ចាត់វិធានការជំរុញឱ្យម្ចាស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) បំពាក់នូវឧបករណ៍ថតរូបភាព ដើម្បីឱ្យប្រាកដថា ពុំមានពលរដ្ឋខ្មែរចូលលេងល្បែង។

៣-ពង្រឹងបន្ថែមការដាក់កំលាំងប្រចាំការរបស់ក្រសួងមហាផ្ទៃ នៅតាមបណ្តាមជ្ឈមណ្ឌលកំសាន្តអេ-ឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) ដើម្បីត្រួតពិនិត្យការអនុវត្ត របស់បណ្តាមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)។

៤-ក្នុងករណីម្ចាស់មជ្ឈមណ្ឌល កំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) ពុំអនុវត្តតាមសារាចរណែនាំលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព រាយការណ៍ និងសំណូមពរជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដកហូតអាជ្ញាប័ណ្ណអាជីវកម្ម និងចាត់វិធានការផ្អាកជាបណ្តោះអាសន្នឬឈានដល់ការបញ្ឈប់អាជីវកម្មមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន)។

៥-ត្រួតពិនិត្យបច្ចេកទេសល្បែង បង្ក្រាបបទល្មើស និងហាមប្រជាពលរដ្ឋខ្មែរចូលក្នុងមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)។

**ប្រការ៣ :** ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព មានសិទ្ធិបង្កើតលេខាធិការដ្ឋានចំរុះ ដើម្បីដំណើរការកិច្ចប្រតិបត្តិការជានាប្រសិទ្ធភាពនៃការអនុវត្តសារាចរលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨។

**ប្រការ៤** : រាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះចាត់ទុកជានិរាករណ៍។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>ចំលងជូនៈ</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង ដែលពាក់ព័ន្ធ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៣ . សរណន

# សារាចរណែនាំ

## ស្តីពីការរៀបចំប្រារព្ធពិធីទិវាវប្បធម៌ជាតិ

## ០៣ មីនា លើកទី១១ ឆ្នាំ២០០៩

## ត្រូវថ្ងៃ ៨កើត ខែ ផល្គុន ឆ្នាំជូត សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៥២

អនុវត្តតាមស្មារតី អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦ ស្តីពី **ការបង្កើតទិវាវប្បធម៌ជាតិ** រាជរដ្ឋាភិបាលបានកំណត់យក ថ្ងៃទី០៣ ខែមីនា រៀងរាល់ឆ្នាំសម្រាប់ប្រារព្ធ **"ទិវាវប្បធម៌ជាតិ"** នៃព្រះរាជាណាចក្រកម្ពុជា និងទទួលបានជោគជ័យជាបន្តបន្ទាប់ស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងធ្វើឱ្យប្រទេសជាតិមានការវិវត្តន៍ឈានឡើងឥតឈប់ឈរលើគ្រប់វិស័យ ។

ដើម្បីរួម ចំណែកបន្តអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២របស់រាជរដ្ឋាភិបាលអាណត្តិទី៤នេះ វិស័យវប្បធម៌បានដើរតួនាទីយ៉ាងសំខាន់សម្រាប់សង្គមកម្ពុជា មិនត្រឹមតែជាចលករជម្រុញបណ្តុះគំនិតខ្មែរឱ្យមានមនសិកាស្នេហាជាតិប៉ុណ្ណោះទេ ថែមទាំងរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការប្រើប្រាស់សក្តានុពលបេតិកភណ្ឌវប្បធម៌ទៀតផង ។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងលើកកម្ពស់វប្បធម៌ជាតិខ្មែរឱ្យកាន់តែល្បីសុះសាយថែមទៀត ។ បន្ទាប់ពី**តំបន់អង្គរ**ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២មក រាជរដ្ឋាភិបាលកម្ពុជាក៏បានស្នើចុះបញ្ជីជាបេតិកភណ្ឌអរូបីនៃមនុស្សជាតិនូវរបាំក្បាច់បូរាណខ្មែរ **"របាំព្រះរាជទ្រព្យ"** កាលពីឆ្នាំ២០០៣ និង**ល្ខោនស្រមោលស្បែកធំ** នៅឆ្នាំ២០០៥ និងជាពិសេសនាពេលកន្លងទៅថ្មីៗ មានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយថ្មីទៀតដែលកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ ប្រាសាទព្រះវិហារដែលជាទីសក្ការៈចូលជាបេតិកភណ្ឌពិភពលោកដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់យូណេស្កូ (UNESCO) ។

ផ្អែកលើមូលដ្ឋាន**វប្បធម៌ជាសេដ្ឋកិច្ច** ក្នុងទស្សនៈ**ប្រែក្លាយព្រះរាជាណាចក្រកម្ពុជាជាមជ្ឈមណ្ឌលកាន់តែសកម្មថែមទៀតក្នុងការផ្សព្វផ្សាយវប្បធម៌ខ្មែរ** ព្រមទាំងឈរលើយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍

**កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ** ផងនោះទើបឆ្នាំនេះរាជរដ្ឋាភិបាលកម្ពុជាបន្តរៀបចំទិវាវប្បធម៌ជាតិ០៣ មីនា លើកទី១១ ដោយសម្រេចយកប្រធានបទ "**បេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ**" សម្រាប់បំផុសមតិជាតិទាំងមូលឱ្យក្លាយទៅជាចលនាមួយផ្តោតការចាប់អារម្មណ៍ទៅលើមរតករបស់ជាតិខ្លួន ក្នុងឱកាសទិវាវប្បធម៌ជាតិ ០៣ មីនា **"លើកទី១១"** នាឆ្នាំ២០០៩នេះ ក្នុងគោលបំណងធ្វើឱ្យប្រជាជនទូទាំងប្រទេស និងលើឆាកអន្តរជាតិ :

-ស្គាល់ និងយល់ដឹងពីតម្លៃនៃបេតិកភណ្ឌវប្បធម៌ជាតិកម្ពុជា

-ចូលរួមផ្តល់តម្លៃដល់វប្បធម៌ជាតិកម្ពុជា

-យកចិត្តទុកដាក់បង្កគ្រប់លទ្ធភាព ក្នុងការប្រើប្រាស់សក្តានុពលបេតិកភណ្ឌវប្បធម៌សម្រាប់ទាក់ទាញវិនិយោគពីបរទេសបានកាន់តែច្រើនឡើងៗ និងជាគោលដៅទេសចរណ៍ប្រចាំតំបន់អាស៊ីអាគ្នេយ៍ផង ។

-ប្រែក្លាយវិស័យវប្បធម៌ឱ្យទៅជាកត្តាជំរុញកំណើនសេដ្ឋកិច្ចយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព តាមរយៈនៃការប្រើប្រាស់សក្តានុពលសម្បត្តិបេតិកភណ្ឌវប្បធម៌រូបី និងអរូបីក្នុងការធ្វើសេវាកម្ម និងផ្តល់សេវាកម្មដោយការបង្កើតការងារសម្រាប់ប្រជាជនកម្ពុជានិងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ផ្អែកតាមស្មារតីខាងលើ គណៈកម្មការអន្តរក្រសួងត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង រៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី១១ ឆ្នាំ២០០៩ ដោយធ្វើការណែនាំក្នុងការរៀបចំអបអរសាទរទិវាវប្បធម៌ជាតិក្រោមប្រធានបទ "**បេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ**" ដូចខាងក្រោម :

១- គ្រប់ក្រសួងស្ថាប័នអាជ្ញាធរដែនដី សហគ្រាសរដ្ឋ និងវិស័យឯកជនគ្រប់លំដាប់ថ្នាក់ ត្រូវលើកទង់ជាតិ ទង់ជ្វាលា បដា ពាក្យស្លោក បិទផ្សាយអាហ្វីសតាមដងផ្លូវសាធារណៈ ទីលានសាធារណៈ និងអង្គភាពរបស់ខ្លួនឱ្យបានព្រមៗគ្នាចាប់ពីថ្ងៃទី ០១ ដល់ ០៧ ខែមីនា ឆ្នាំ២០០៩ ។

២- ក្រសួងព័ត៌មានត្រូវរៀបចំកម្មវិធីផ្សាយពិសេសតាមកាសែត ទស្សនាវដ្តី វិទ្យុជាតិ វិទ្យុ FM វិទ្យុ ទូរទស្សន៍ពីខ្លឹមសារនៃទិវាវប្បធម៌ជាតិលើកទី១១ ឆ្នាំ២០០៩នេះ ដោយប្រើប្រាស់ឯកសារជំនួយស្មារតីស្តីពី ទិវាវប្បធម៌ជាតិ លើកទី១១ និងឯកសារពាក់ព័ន្ធផ្សេងទៀតសំដៅប្រែក្លាយឱ្យសាធារណៈជនយល់បានកាន់តែច្បាស់ពីសារៈប្រយោជន៍នៃ "**បេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ**" ។

៣- ក្រសួងអប់រំយុវជន និងកីឡា ត្រូវបើកកម្មវិធីប្រកួតប្រជែងក្នុងមជ្ឈដ្ឋានសិស្ស និស្សិត តាមរយៈ "**សួរ-ឆ្លើយ**" នូវខ្លឹមសារស្តីពីបេតិកភណ្ឌវប្បធម៌ជាតិ ។

៤- ក្រសួងទេសចរណ៍ ត្រូវចែកផ្សាយរាល់ឯកសារស្តីពីទេសចរណ៍វប្បធម៌ និងឯកសារដែលពាក់ព័ន្ធជូនដល់គ្រប់ទីភ្នាក់ងារទេសចរណ៍ជាតិ អន្តរជាតិ ដើម្បីពង្រីកទីផ្សារ និងបង្កើនភាពទាក់ទាញ ។

៥- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំដល់គ្រប់ស្ថានទូត កុងស៊ុល នៅបរទេស ឱ្យរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី១១តាមលទ្ធភាពជាក់ស្តែង ។

៦- ក្រសួងធម្មការ និងកិច្ចការសាសនា ត្រូវបំផុសចលនាដល់ព្រះសង្ឃ និងគ្រប់សាសនិក ឱ្យរៀបចំកម្មវិធីផ្សព្វផ្សាយខ្លឹមសារទិវាវប្បធម៌ជាតិ នៅតាមទីវត្តអារាម ព្រះវិហារ និងទីសក្ការៈរបស់ខ្លួនទៅតាមការជាក់ស្តែង។

៧- អាជ្ញាធរ "**អប្សរា** " អាជ្ញាធរ "**ព្រះវិហារ**" ត្រូវរៀបចំពិធីមីទ្ទីញអបអរទិវាវប្បធម៌ជាតិលើកទី១១ នៅផ្ទាល់នឹងរមណីយដ្ឋានប្រាសាទបុរាណទៅតាមការជាក់ស្តែង។

៨- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើជាលេខាធិការដ្ឋានក្នុងការរៀបចំឯកសារឃោសនាបម្រើឱ្យទិវាវប្បធម៌ជាតិទាំងមូល និងដឹកនាំឱ្យគ្រប់ខេត្ត និងរាជធានីភ្នំពេញរៀបចំទិវាវប្បធម៌ជាតិក្នុងភូមិសាស្ត្ររបស់ខ្លួន ជាពិសេសត្រូវបែងចែកមន្ត្រីជាន់ខ្ពស់ចុះទៅតាមបណ្តាខេត្ត និងរាជធានី ដើម្បីសហការជាមួយអាជ្ញាធរដែនដីរៀបចំពិធីនេះ។ម្យ៉ាងទៀតត្រូវណែនាំឱ្យគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីនិងគ្រប់ខេត្តរៀបចំកម្មវិធីសម្តែងទស្សនីយភាពសិល្បៈនៅតាមទីលានសាធារណៈ ជូនសាធារណៈជនទស្សនាកំសាន្ត ដោយមានខ្លឹមសារស្របនឹងប្រធានបទ " **បេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ** "។

៩- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវមានផែនការណែនាំរៀបចំបែងចែកកងកម្លាំងសម្រាប់ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងប្រារព្ធពិធីអបអរបុណ្យទិវាវប្បធម៌ជាតិ លើកទី១១ ឱ្យមានសុវត្ថិភាពល្អប្រសើរ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គភាព រោងចក្រ សហគ្រាសរដ្ឋ និងវិស័យឯកជនទាំងអស់ទូទាំងប្រទេស ត្រូវរៀបចំអបអរសាទរទិវាវប្បធម៌ជាតិតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅអនុវត្តឱ្យបានជោគជ័យកាន់តែប្រសើរឡើងថែមទៀតនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលអាណត្តិទី៤។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**

- ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
- ខុទ្ទកាល័យព្រឹទ្ធសភា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់អាជ្ញាធរជាតិ
- សាលារាជធានី និងគ្រប់ខេត្ត
- កាលប្បវត្តិ-ឯកសារ

## ពាក្យស្លោក ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១១ ឆ្នាំ២០០៩

១. អបអរសាទរយ៉ាងក្លៀវក្លាទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១១ ឆ្នាំ២០០៩

២. ជាតិ សាសនា ព្រះមហាក្សត្រ

៣. ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៤. ជយោ ! ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌវប្បធម៌ពិភពលោកនៅថ្ងៃទី ០៧ កក្កដា ២០០៨

៥. មេត្តា ! ប្រើប្រាស់ធនធានបេតិកភណ្ឌវប្បធម៌សម្រាប់កសាងសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព

៦. មេត្តា ! ថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានគង់វង្សជាអមតៈ

៧. ទាំងអស់គ្នាដើម្បីការពារបេតិកភណ្ឌវប្បធម៌ជាតិ

៨. បេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីយើងទាំងអស់គ្នា !

៩. បេតិកភណ្ឌវប្បធម៌ជាតិជាសក្តានុពលសេដ្ឋកិច្ចរបស់កម្ពុជា !

១០. បេតិកភណ្ឌវប្បធម៌ជាតិ ជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ !

១១. បេតិកភណ្ឌវប្បធម៌ជាតិ ជាគ្រឹះនៃទេសចរណ៍ជាតិ !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៦ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន ដើម្បីជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ សំរាប់គំរោងហិរញ្ញប្បទានដោយធនាគារពិភពលោក

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៥៨៧ សហវ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីលទ្ធកម្មរួម សំរាប់គំរោងជំនួយរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមតំរូវការចាំបាច់ និងដោយមានការព្រមព្រៀងជាមួយធនាគារពិភពលោក

**សម្រេច**

**ប្រការ ១ :** បង្កើតគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន ដើម្បីជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ ទទួលបន្ទុកកិច្ចលទ្ធកម្មគំរោងហិរញ្ញប្បទានដោយធនាគារពិភពលោក ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ខន់ វិសុទ្ធ** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ឡី មេង** | រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣- ឯកឧត្តម **គុយ ពុំ** | អនុរដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤- លោក **ហេង តារិទ្ធ** | អគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន | សមាជិក |
| ៥- លោក **ច ម៉េងចូ** | អគ្គនាយករងបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| ៦- លោក **ហេង គុណលាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ថាមពលនៃអគ្គនាយកដ្ឋានថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៨- លោក **អ៊ុច គឹមយ៉ុន** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- លោក **សេង យូអ៊ាន់** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែករដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩- លោក **ប៉ែន ធីរុទ្ធ** | អនុប្រធានទី ១ នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកអចិន្ត្រៃយ៍ |
| ១០- លោក **តូច ចន្ទក្រឹស្នា** | ប្រធានការិយាល័យធនាគារពិភពលោក នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក **ចេ សាវុន** | ប្រធានការិយាល័យគ្រប់គ្រងថវិកាវិនិយោគសាធារណៈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- លោក **ប៉ែន ប៊ុរិន** | ប្រធានការិយាល័យគណនេយ្យនៃអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ១៣- លោក **ខួន លក្ខណា** | អនុប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- លោក **សៀង គង់** | តំណាងគណៈកម្មាធិការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១៥- លោក **ពៅ សុភាព** | មន្ត្រីលទ្ធកម្មនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |

**១៦- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**១៧- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន**

**១៨- តំណាងអគ្គិសនីកម្ពុជា**

**១៩- តំណាងធនាគារជាតិ**

**ប្រការ ២** : គណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័នមានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ធានាលើសង្គតភាពនៃនីតិវិធីលទ្ធកម្មជាធរមាន
- ចូលរួមបើកឯកសារដេញថ្លៃ និងត្រួតពិនិត្យសំណើឯកសារដេញថ្លៃ
- វាយតំលៃលើសំណើដេញថ្លៃ និងចរចាតំលៃ
- ផ្តល់អនុសាសន៍ និងសំរេចលើលទ្ធផលនៃការជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ
- ពិនិត្យ និងសំរេចលើលក្ខខណ្ឌការងារ (Term of References) របស់ភ្នាក់ងារលទ្ធកម្មឯករាជ្យ
- ត្រួតពិនិត្យការអនុវត្តកិច្ចសន្យារបស់ភ្នាក់ងារលទ្ធកម្មឯករាជ្យ

**ប្រការ ៣** : សមាជិកទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន អាចប្រគល់សិទ្ធិដល់សមាជិកណាម្នាក់ ធ្វើជាអ្នកដឹកនាំ សំរបសំរួលអង្គប្រជុំជំនួសបាន ។

**ប្រការ ៤** : ក្នុងករណីជួបប្រទះបញ្ហាវេទយិតភាព គណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័នត្រូវរាយការណ៍ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការណែនាំ និងសំរេច ។

**ប្រការ ៥** : ភ្នាក់ងារប្រតិបត្តិគំរោងដែលពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្ត ប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ភ្នាក់ងារប្រតិបត្តិគំរោង
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៩៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## វិធាន និងនីតិវិធី
## ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យ ប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

អោយទៅជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ៩៣០ សហវ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១.** បំណុលសារពើពន្ធ គឺជាប្រាក់ពន្ធអាករគ្រប់ប្រភេទ ដែលមិនបានបង់នៅពេលដល់កំណត់ត្រូវបង់ ។ បំណុលពន្ធ រួមមានប្រាក់ពន្ធអាករ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលទាក់ទិន ។ ផ្អែកតាមកថាខ័ណ្ឌ ៤ នៃ មាត្រា ១០៧ នៃច្បាប់ស្តីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិប្រមូលបំណុលពន្ធ រហូតដល់ថ្ងៃដែលបំណុលពន្ធ ត្រូវបានចាត់ទុកជាប្រាក់ពន្ធ មិនអាចប្រមូលបាន ។

បំណុលពន្ធដែលត្រូវបានចាត់ទុកជា ប្រាក់ពន្ធមិនអាចប្រមូលបាន ត្រូវមានលក្ខណៈ វិនិច្ឆ័យ ទាំងបីដូចខាងក្រោម :

១- អ្នកជាប់ពន្ធបាត់ខ្លួនយ៉ាងតិច ៥ ឆ្នាំ មកហើយ ឬទទួលរងគ្រោះដោយសារប្រធានស័ក្តិ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរឃុំ-សង្កាត់ ឬស្ថាប័នមានសមត្ថកិច្ច ។ សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "ប្រធានស័ក្តិ" សំដៅដល់បាតុភូតធម្មជាតិ បាតុភាពនយោបាយ ឬបាតុភាពដទៃទៀតដែលបង្កឱ្យមានគ្រោះមហន្តរាយ

២- បំណុលពន្ធចុងក្រោយ មានអាយុកាលយ៉ាងតិច៥ឆ្នាំ ក្រោយការិយបរិច្ឆេទកត់ត្រាបំណុលពន្ធ

៣- អ្នកជាប់ពន្ធគ្មានលទ្ធភាពទូទាត់បំណុលពន្ធ ដោយមានការបញ្ជាក់ពីរដ្ឋបាលសារពើពន្ធ នៅទីកន្លែង ។ ទោះបីជាបំណុលពន្ធ ត្រូវបានចាត់ទុកជាប្រាក់ពន្ធមិនអាចប្រមូលបានរួចហើយក្តី រដ្ឋបាលសារពើពន្ធអាចអនុវត្តការទារបំណុលពន្ធនេះបានគ្រប់ពេលវេលា ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា បំណុលពន្ធអាចប្រមូលបានវិញ ។

**ប្រការ ២.** សិទ្ធិសំរេចចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន ជាសមត្ថកិច្ចរបស់ :

១- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់តិចជាង ឬស្មើនឹងដប់លានរៀល ( ១០,000,000 ៛ )

២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់លើសពីដប់លានរៀល ( ១០,000,000 ៛ ) ។

**ប្រការ ៣.** ដើម្បីចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន អគ្គនាយកដ្ឋានពន្ធដារត្រូវបង្កើតក្រុមការងារមួយ ដែលមានសមាសភាព និងភារកិច្ច ដូចខាងក្រោម :

១- សមាសភាពក្រុមការងារ :

- អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ...........................................ជាប្រធាន
- ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ..............................ជាអនុប្រធាន
- ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬប្រធានសាខាពន្ធដារ ខេត្ត-ក្រុង-ខ័ណ្ឌ.................................................................ជាសមាជិក
- ប្រធានការិយាល័យបំណុលពន្ធនៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ...ជាលេខាធិការ

២- ភារកិច្ចរបស់ក្រុមការងារ :

- ពិនិត្យនិងផ្ទៀងផ្ទាត់សំណើសុំរបស់ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារ ខេត្ត-ក្រុង-ខ័ណ្ឌ ស្តីពីការចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន
- ចុះត្រួតពិនិត្យផ្ទាល់ដល់គ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងស្នាក់នៅរបស់អ្នកជាប់ពន្ធ ដែលជាកម្មវត្ថុនៃការស្នើសុំ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងលើកសំណើជូនអគ្គនាយកនៃ អគ្គនាយកដ្ឋានពន្ធដារ ឬនិង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។

**ប្រការ ៤.** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**គាត ឈន់**

<u>ចម្លងជូន</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

លេខ : ០៧៩ ឧសរ.ក.ឱ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦០៦/ ០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៦៦៣/០៨ គ.វ.ក ចុះថ្ងៃទី០៤.១២.២០០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហេមតិច អ៊ិនធើណេសិនណល (ខេមបូឌា) ចុះថ្ងៃទី២៧.១១.២០០៨

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហេមតិច អ៊ិនធើណេសិនណល (ខេមបូឌា) ( HEMTEX INTERNATIONAL (CAMBODIA) CO.,LTD.) តំណាងដោយ លោក TSAO, HSIAO-CHUNG សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 135165009 ចុះថ្ងៃទី២៧.១១.២០០៧ បង្កើតរោងចក្រ "កាត់ដេរ ចាក់ និងបោះពុម្ពសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហេមតិច អ៊ិនធើណេសិនណល (ខេមបូឌា) (HEMTEX INTERNATIONAL (CAMBODIA) )" មានទីតាំងស្ថិតនៅ ភូមិព្រៃរការ ឃុំឆកឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ប្រការ២: ក្រុមហ៊ុនត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងត្រូវរៀបចំរោងចក្រទៅតាមប្លង់ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរ ចាក់ និងបោះពុម្ពសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៤: ក្រុមហ៊ុន ត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

